ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៣៧១/១៥ គ.ជ.ប.ជ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមការងារអនុវត្តន៍ច្បាប់

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខៈ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចរាជរដ្ឋាភិបាល លេខ ១៤៥ សសរ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពនៃក្រុមការងារអនុវត្តច្បាប់របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ **ប្រធាន**

២. លោកជំទាវ ឧ.ឯក **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ **អនុប្រធានអចិន្ត្រៃយ៍**
៣. ឯកឧត្តម **សុខ រឿន** អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ អនុប្រធាន
៤. លោកជំទាវ **អ៊ុំ សាម៉ុល** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល អនុប្រធាន
៥. ឯកឧត្តម ឧ.ទោ **ស៊ុន រ៉ូ** អគ្គលេខាធិការរង គ.ជ.ប.ជ អនុប្រធាន
៦. ឯកឧត្តម ឧ.ឯក **ប៉ុល ភិធេយ្យ**ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ក្រសួងមហាផ្ទៃ អនុប្រធាន
៧. លោក **សេខ ពុទ្ធី** ប្រធាននាយកដ្ឋានកិច្ចការច្បាប់ និងស្ថិតិព្រហ្មទណ្ឌ ក្រសួង យុត្តិធម៌ អនុប្រធាន
៨. ឯកឧត្តម **តូច ចាន់នី** អគ្គនាយក បច្ចេកទេស ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា អនុប្រធាន
៩. លោកជំទាវ ឧ.ឯក **ឌុច ដាណា** អគ្គនាយករង អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ សមាជិក
១០. លោកជំទាវ **សាខឿន សាវ៉ាតឌី**អគ្គនាយករងអភិវឌ្ឍសង្គម ក្រសួងកិច្ចការនារី សមាជិក
១១. លោក **ជួប ណារ៉ាត** អគ្គនាយករង អគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
១២. ឧត្តមសេនីយ៍ទោ **ញឹម សំបួន**នាយរងទីចាត់ការ នៃអគ្គបញ្ជាការដ្ឋាន ទីចាត់ការ ការងារព្រំដែន ក្រសួងការពារជាតិ សមាជិក
១៣. ឧត្តមសេនីយ៍ទោ **ប៉ាក់ យូលាង**អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ សមាជិក
១៤. ឧត្តមសេនីយ៍ត្រី **កែវ រតនា** ស្នងការរង ស្នងការដ្ឋានយុត្តិធម៌កងរាជអាវុធហត្ថ លើផ្ទៃប្រទេស សមាជិក
១៥. ឧត្តមសេនីយ៍ត្រី **ម៉ុក ម៉ុនឈាង** អនុប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
១៦ លោក **គឹម សុវណ្ណា**អនុប្រធាននាយកដ្ឋានច្បាប់កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
១៧. វរសេនីយ៍ទោ **សឿ ដារ៉ា** នាយការិយាល័យបទល្មើសជួញដូរមនុស្ស ស្នងការដ្ឋានយុត្តិធម៌ កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៨. តំណាង អង្គការដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ សមាជិក

**ប្រការ២.**-

ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារអនុវត្តច្បាប់ ត្រូវអនុវត្តតាមតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ៥ នៃសេចក្តីសម្រេចគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពី ការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព ។ ប្រធានក្រុមការងារ អាចចាត់តាំងមន្ត្រី ជាជំនួយតាមការចាំបាច់ ។

អង្គការដៃគូពាក់ព័ន្ធ ជាតិ និងអន្តរជាតិដែលមានគោលដៅស្របទៅនឹងភារកិច្ចដែលកំណត់ដោយសេចក្តីសម្រេចលេខ ០៩៤/១៤ សសរ ខាងលើនេះ អាចស្នើសុំចូលជាសមាជិកក្រុមការងារ មកប្រធានក្រុមការងារអនុវត្តច្បាប់ និងចាត់តំណាងផ្លូវការមកចូលរួម តាមការអញ្ជើញរបស់ប្រធានក្រុម ។

**ប្រការ៣.-**

អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យក្រសួងមហាផ្ទៃ
- សេនាធិការដ្ឋានអគ្គស្នងការនគរបាលជាតិ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ
- ក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ
- សាមីខ្លួនដូចប្រការ១
- ឯកសារ កាលប្បវត្តិ